ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកណ្តាល
លេខ........០៤៣.......ដក.តក

ក្រសួងមុខងារសាធារណៈ រដ្ឋបាល
ចូល
លេខៈ............
មកដល់ថ្ងៃទី............ខែ............ឆ្នាំ............
ម៉ោង.......៤.៣០.........

# ដីកា

## ស្តីពី

## ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ នៅរដ្ឋបាលខេត្តកណ្តាល ដើម្បីជំរុញការអនុវត្ត ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០១៥-២០១៨

## អភិបាល នៃគណៈអភិបាលខេត្តកណ្តាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៦៣ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១៤ ស្តីពីការតែងតាំងអភិបាលនៃគណៈអភិបាលខេត្តកណ្តាល
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងលិខិតលេខ ១៨៤៦ មស.គករ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ
- យោងលិខិតលេខ ១៥២០ ស.ជ.ណ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ
- បានទទួលការអនុម័តពីក្រុមប្រឹក្សាខេត្តកណ្តាល ក្នុងកិច្ចប្រជុំសាមញ្ញលើកទី២៧ អាណត្តិទី២ កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅរដ្ឋបាលខេត្តកណ្តាល ដើម្បីជំរុញការអនុវត្ត ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០១៥ ២០១៨ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១.ឯកឧត្តម | **ជាវ តាយ** | អភិបាលរងខេត្ត | ប្រធាន |
| ២.លោក | **នួចប៉េង ច័ន្ទតារា** | រដ្ឋបាលរដ្ឋបាលសាលាខេត្ត | អនុប្រធាន |
| ៣.លោក | **ប៉ុល ថូ** | ប្រធានមន្ទីរមុខងារសាធារណៈខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |

| | | | |
|---|---|---|---|
| ៤.លោកស្រី | **ហែម តុម្ភ៉ាឡៃ** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ៤.លោកស្រី | **តុប ស៊ីថា** | ប្រធានរតនាគារខេត្ត | សមាជិក |
| ៥.លោក | **ហេង ធឿម** | អភិបាលក្រុងតាខ្មៅ | សមាជិក |
| ៦.លោក | **ញឹម វណ្ណឌិន** | អភិបាលស្រុកស្អាង | សមាជិក |
| ៧.លោក | **អេង ហោគ្វ** | អភិបាលស្រុកកោះធំ | សមាជិក |
| ៨.លោក | **បូរ ណារ៉េត** | អភិបាលស្រុកកណ្ដាលស្ទឹង | សមាជិក |
| ៩.លោក | **នឹម នីរ៉ាដេត** | អភិបាលស្រុកអង្គស្នួល | សមាជិក |
| ១០.លោក | **តាំង ម៉េងលាន** | អភិបាលស្រុកមុខកំពូល | សមាជិក |
| ១១.លោក | **តុង ស៊ីវមី** | អភិបាលស្រុកពញាឮ | សមាជិក |
| ១២.លោក | **គង់ សោភ័ណ្ឌ** | អភិបាលស្រុកខ្សាច់កណ្ដាល | សមាជិក |
| ១៣.លោក | **ប៊ុន ផេង** | អភិបាលស្រុកល្វាឯម | សមាជិក |
| ១៤.លោក | **អ៊ូ ឈាង** | អភិបាលស្រុកកៀនស្វាយ | សមាជិក |
| ១៥.លោក | **នូវ សំណាង** | អភិបាលស្រុកលើកដែក | សមាជិក |
| ១៦.លោក | **គីម សម្បុក** | នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស | សមាជិក |
| ១៧.លោកស្រី | **ទ៉ូវ មួយគា** | នាយិកាទីចាត់ការហិរញ្ញវត្ថុ | សមាជិក |
| ១៨.លោក | **ស៊ិន សម្បត្តិ** | នាយកទីចាត់ការរដ្ឋបាល | សមាជិក |
| ១៩.លោក | **ទ្រី ប៊ុនហ៊ាង** | នាយកទីចាត់ការផែនការ និងវិនិយោគ | សមាជិក |
| ២០.លោក | **បូ សាវឿន** | នាយកទីចាត់ការអន្តរវិស័យ | សមាជិក |
| ២១.លោក | **ខុន លីម៉ូរ៉ា** | ប្រធានអង្គភាពលទ្ធកម្មរដ្ឋបាលខេត្ត | សមាជិក |
| ២២.លោក | **ឡេង ឈុន** | អនុប្រធានមន្ទីរមុខងារសាធារណៈ | មន្ត្រីបង្គោល |
| ២៣.លោក | **អ៊ីវ ហេង** | មន្ត្រីនៃមន្ទីរមុខងារសាធារណៈ | មន្ត្រីបង្គោល |

**ប្រការ ២.-**

ក្រុមការងារនេះមានតួនាទីភារកិច្ចដូចខាងក្រោម ៖

- ទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សា និងគណៈអភិបាលខេត្តក្នុងការគ្រប់គ្រង និងដឹកនាំគ្រប់ការងារពាក់ព័ន្ធនឹងកម្មវិធី យុទ្ធសាស្ត្រ និងសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្ត ។
- សម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្ត ជាមួយក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ។
- សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពការងារ កែទម្រង់រដ្ឋបាលសាធារណៈ ។
- រៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខេត្ត ។/.

- រៀបចំរបាយការណ៍ ស្តីពីវឌ្ឍនភាពឲ្យបានទៀងទាត់រៀងរាល់ត្រីមាសមកលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ។
- រៀបចំរបាយការណ៍ ស្តីពីវឌ្ឍនភាព នៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈជូនក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈក្រសួងមហាផ្ទៃ ដើម្បីធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជ្រាប និងផ្តល់គោលការណ៍ណែនាំអនុវត្ត ។
- ផ្តល់កិច្ចសហការ និងសម្របសម្រួលជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ តាមរយៈមន្ត្រីបង្គោល ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈនៅរដ្ឋបាលខេត្ត ។
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**ប្រការ ៣.-**

នាយករដ្ឋបាលសាលាខេត្ត ប្រធានមន្ទីរ-អង្គភាព នាយកទីចាត់ការ-ប្រធានអង្គភាពចំណុះសាលាខេត្ត អភិបាលក្រុង-ស្រុក និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើត្រូវអនុវត្តដីកានេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

កណ្តាល ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦

**អភិបាលខេត្ត**

ម៉ៅ ភិរុណ

**<u>ចម្លងជូន</u>**
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "<u>ដើម្បីគោរពជូនជ្រាប</u>"
- ដូចប្រការ៣ "<u>ដើម្បីអនុវត្ត</u>"
- ឯកសារ កាលប្បវត្តិ